សម្គាល់៖ សាលក្រមនេះជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគំរូទេ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

0140

**សាលាដំបូងខេត្តព្រះវិហារ**
សំណុំរឿងរដ្ឋប្បវេណីលេខ៣៥
ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧
សាលក្រមរដ្ឋប្បវេណីលេខ ០៩"ឃ"
ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩

## សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះវិហារ

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩

**ចៅក្រមជំនុំជម្រះ**

លោក **ឡៀន ស្រស់** ចៅក្រម នៃសាលាដំបូងខេត្តព្រះវិហារ

**ក្រឡាបញ្ជី**

លោក **សន លាង** ក្រឡាបញ្ជី នៃសាលាដំបូងខេត្តព្រះវិហារ

**ដើមចោទ៖** ឈ្មោះ ង ភេទស្រី អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ មានទីលំនៅសព្វថ្ងៃ ខេត្តព្រះវិហារ។

**ចុងចម្លើយ៖** ឈ្មោះ ច ភេទប្រុស អាយុ៦០ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ ខេត្តព្រះវិហារ។

## អង្គហេតុ និងចំណុចវិវាទ

### ក.ខ្លឹមសារ នៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

១/.សុំទាមទារប្រាក់ដើមជំពាក់ចំនួន ៤៨០០ ដុល្លារ(បួនពាន់ប្រាំបីរយដុល្លារអាមេរិក)

២/.ទាមទារសំណងជម្ងឺចិត្តចំនួន ២០០០ (ពីរពាន់)ដុល្លារអាមេរិក

៣/.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ

### ខ.ដំណើររឿងក្ដី និងចំណុចវិវាទ

#### ខ.១. ការសង្ខេបអំពីរឿងក្ដី

នាងខ្ញុំឱ្យឈ្មោះ ច ខ្ចីប្រាក់ចំនួនពីរលើក ដោយលើកទីមួយ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ចំនួន ១២,០០០,០០០(ដប់ពីរលាន)រៀល លើកទីពីរ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៥ ចំនួន ១៨,០០០,០០០(ដប់ប្រាំបីលាន)រៀល ដោយមានកិច្ចសន្យាខ្ចីប្រាក់ និងកិច្ចសន្យាសងវិញរយៈពេលពីរខែគ្រប់ចំនួនតែមិនព្រមសងឱ្យនាងខ្ញុំនោះទេ រហូតដល់នាងខ្ញុំបានទៅរឹបអូសយកត្រាក់ទ័រនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៦ ហើយឈ្មោះ ច បានឱ្យនាងខ្ញុំប្រគល់ត្រាក់ទ័រឱ្យវិញដោយយល់ព្រមធ្វើកិច្ចសន្យាសងប្រាក់នៅឃុំស្រអែម ជារៀងរាល់ខែចាប់ពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ក្នុងមួយខែចំនួន ១០០០(មួយពាន់)ដុល្លារអាមេរិក រហូតដល់គ្រប់ចំនួនប្រាក់ដែលព្រមព្រៀងគ្នាសងក្នុងចំនួន ៦០០០(ប្រាំមួយពាន់)ដុល្លារអាមេរិក ប៉ុន្តែឈ្មោះ ច

សម្គាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

បានសងប្រាក់មកឲ្យនាងខ្ញុំបានចំនួន ១២០០(មួយពាន់ពីររយ)ដុល្លារអាមេរិក ប៉ុណ្ណោះ នៅខែបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ននេះឈ្មោះ ច ពុំដែលបានសងប្រាក់ដូចមានចែងក្នុងកិច្ចសន្យានោះទេ។

### ខ.២.អង្គហេតុដែលគ្មានវិវាទ

ចុងចម្លើយឈ្មោះ ច បានខ្ចីប្រាក់ពីដើមចោទចំនួនពីរលើក ដោយលើកទីមួយចំនួន ១២,០០០,០០០(ដប់ពីរលាន)រៀល តាមកិច្ចសន្យាចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ហើយគាត់ពុំទាន់សងនោះទេ ក៏មកខ្ចីលើកទីពីរ ចំនួន ១៧,៨៣០,០០០(ដប់ប្រាំពីរលានប្រាំបីសែនបីម៉ឺន)រៀល ហើយក៏អត់សងទៀត រហូតដល់ឆ្នាំ២០១៦ ក៏បានធ្វើកិច្ចសន្យាព្រមព្រៀងរវាងខ្ញុំនិងឈ្មោះ ច ដែលមានការទទួលស្គាល់ដោយលោកមេឃុំ ក្នុងការទទួលស្គាល់ថាឈ្មោះ ច ជំពាក់ប្រាក់ខ្ញុំចំនួន ៥៨៥០ (ប្រាំពាន់ប្រាំបីរយហាសិប)ដុល្លារអាមេរិក ដោយការសម្របសម្រួលគ្នាហើយក្នុងកិច្ចសន្យាបានព្រមព្រៀងគ្នាថា ឈ្មោះ ច ត្រូវសងលុយមកខ្ញុំក្នុងមួយខែចំនួន ១០០០(មួយពាន់)ដុល្លារអាមេរិក រហូតដល់គ្រប់ចំនួន។ ប៉ុន្តែឈ្មោះ ច បានអនុវត្តកិច្ចសន្យានេះតែម្តងគត់ គឺសងប្រាក់មកខ្ញុំបានតែចំនួន ១០០០(មួយពាន់)ដុល្លារអាមេរិក ក្រោយមកទៀតគាត់ឈប់សងប្រាក់ខ្ញុំរហូតដល់បច្ចុប្បន្ននេះ។ ចំពោះប្រាក់ដែលនៅសល់មានចំនួនសរុប ៤៨៥០(បួនពាន់ប្រាំបីរយហាសិប)ដុល្លារអាមេរិក ប៉ុន្តែខ្ញុំលះបង់ការទាមទារចំនួន ៥០(ហាសិប)ដុល្លារអមេរិក ហើយខ្ញុំទាមទារតែចំនួន ៤៨០០(បួនពាន់ប្រាំបីរយ)ដុល្លារ អាមេរិកតែប៉ុណ្ណោះ ដូចដែលមានចែងក្នុងកម្មវត្ថុនៃពាក្យបណ្តឹងដែលបានទាមទារអោយតុលាការចេញ សាលក្រម។

### ខ.៣.ចំណុចវិវាទ

-គ្មាន។

### ខ.៤.ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ

-ដើមចោទឈ្មោះ ផ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ឈ្មោះ ច បានខ្ចីប្រាក់របស់ខ្ញុំពីរលើក លើកទីមួយចំនួន ១២,០០០,០០០(ដប់ពីរ លាន)រៀល តាមកិច្ចសន្យាចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ហើយគាត់ពុំទាន់សងនោះទេ ក៏មកខ្ចីលើកទីពីរចំនួន ១៧,៨៣០,០០០(ដប់ប្រាំពីរលានប្រាំបីសែនបីម៉ឺន)រៀល ហើយក៏អត់សងទៀត រហូតដល់ឆ្នាំ២០១៦ ក៏បានធ្វើ កិច្ចសន្យាព្រមព្រៀងរវាងខ្ញុំនិងឈ្មោះ ច ដែលមានការទទួលស្គាល់ដោយលោកមេឃុំ ក្នុងការទទួលស្គាល់ថាឈ្មោះ ច ជំពាក់ប្រាក់ខ្ញុំចំនួន ៥៨៥០(ប្រាំពាន់ប្រាំបីរយហាសិប) ដុល្លារអាមេរិក ដោយការសម្របសម្រួលគ្នាហើយក្នុងកិច្ចសន្យាបានព្រមព្រៀងគ្នាថា ឈ្មោះ ច ត្រូវសងលុយមកខ្ញុំក្នុងមួយខែចំនួន ១០០០(មួយពាន់)ដុល្លារអាមេរិក រហូតដល់គ្រប់ចំនួន។ ប៉ុន្តែឈ្មោះ ច បានអនុវត្តកិច្ចសន្យានេះតែម្តងគត់ គឺសងប្រាក់មកខ្ញុំបានតែចំនួន ១០០០(មួយពាន់)ដុល្លារអាមេរិក ក្រោយមកទៀតគាត់ឈប់សងប្រាក់ខ្ញុំរហូតដល់បច្ចុប្បន្ននេះ។ ចំពោះប្រាក់ដែលនៅសល់មានចំនួនសរុប ៤៨៥០(បួនពាន់ប្រាំបីរយហាសិប) ដុល្លារអាមេរិក ប៉ុន្តែខ្ញុំលះបង់ការទាមទារចំនួន ៥០(ហាសិប)ដុល្លារអមេរិក ហើយខ្ញុំទាមទារតែចំនួន ៤៨០០ (បួនពាន់ប្រាំបីរយ)ដុល្លារអាមេរិកតែប៉ុណ្ណោះ ដូចដែលមានចែងក្នុងកម្មវត្ថុនៃពាក្យបណ្តឹងដែលបានទាមទារអោយតុលាការចេញសាលក្រម។

សម្គាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ចំពោះការទាមទារជម្ងឺចិត្តចំនួន ២០០០(ពីរពាន់)ដុល្លារអាមេរិក ដោយសារតែខ្ញុំខាតបង់ពេលវេលា និងសោហ៊ុយផ្សេងៗក្នុងដំណើរការនៃនីតិវិធីបណ្តឹងទាមទារប្រាក់តាំងពីភូមិឃុំ ស្រុករហូតដល់តុលាការ។ ដោយឡែកចំពោះប្រាក់ប្រដាប់ក្តីវិញ គឺខ្លួនទាមទារអោយចុងចម្លើយជាអ្នកទទួលបន្ទុក មូលហេតុដោយសារតែខ្ញុំបានបង់ប្រាក់ប្រដាប់ក្តីតុលាការទាំងអស់រួចហើយ តាមច្បាប់អ្នកជំពាក់ប្រាក់ ឬអ្នកចាញ់ត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តីតុលាការ។

## សំអាងហេតុ

**ក**.ផ្អែកតាមកិច្ចសន្យាចងការប្រាក់ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤,កិច្ចសន្យាចងការប្រាក់ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៥ ,កិច្ចសន្យា ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦,កិច្ចសន្យាចងការប្រាក់(អ្នកធានា) ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ និងការអះអាងរបស់ដើមចោទនៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ព្រមទាំងនៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ នាពេលសវនាការ។ ការអះអាងនេះ យោងតាមបញ្ញត្តិនៃមាត្រា ២០១ កថាខណ្ឌ២ វគ្គខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា បើចុងចម្លើយមិនបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុហើយបើយល់ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ តុលាការត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទដោយសាលក្រមកំបាំងមុខ តែបើយល់ឃើញថា ការទាមទាររបស់ដើមចោទមិនត្រឹមត្រូវទេ តុលាការត្រូវច្រានចោលការទាមទារនោះ។ ដូចនេះ តុលាការទទួលស្គាល់ថាចុងចម្លើយបានទទួលប្រាក់ពីដើមចោទចំនួន ៤៨០០(បួនពាន់ប្រាំបីរយ)ដុល្លារអាមេរិក។

**ខ**.ដើមចោទទាមទារប្រាក់ពីចុងចម្លើយចំនួន ២០០០(ពីរពាន់)ដុល្លារអាមេរិក ជាសំណងជម្ងឺចិត្ត។ ផ្អែកតាមមាត្រា ៤០០ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីចែងថា តុលាការគឺអាចបង្គាប់ឱ្យកូនបំណុលសងសំណងនៃការខូចខាតផ្លូវចិត្តដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលបាន ប៉ុន្តែគោលបំណង នៃមាត្រានេះសំណងជម្ងឺចិត្តត្រូវបានទទួលស្គាល់តែក្នុងករណីដែលបានកើតមាននូវការបំពានប្រយោជន៍បុគ្គលដូចជា កិត្តិយស អាយុជីវិត និងរូបរាងកាយជាដើម។ ការទាមទាររបស់ដើមចោទមិនមានលក្ខណៈត្រឹមត្រូវ គប្បីតុលាការសម្រេចច្រានចោល។

**គ**.នៅក្នុងរឿងក្តីស្តីពីការទាមទារប្រាក់នេះ ដើមចោទបានបង់ប្រាក់ប្រដាប់ក្តីទាក់ទងជាមួយនីតិវិធីនៅតុលាការ ហើយចុងចម្លើយបានចាញ់ក្តី ហេតុនេះបន្ទុកនៃប្រាក់ប្រដាប់ក្តី គប្បីសម្រេចឱ្យចុងចម្លើយជាអ្នកទទួលបន្ទុក។

**សរុបជារួម តុលាការនឹងសម្រេចអំពី "រឿងក្តីស្តីពីការទាមទារឱ្យសងប្រាក់កម្ចី នៃរឿងក្តីនេះ" ដូចខាងក្រោម**

## សេចក្តីសម្រេចបញ្ចប់

១-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច សងប្រាក់ដើមចំនួន ៤៨០០$(បួនពាន់ប្រាំបីរយ) ដុល្លារអាមេរិក ទៅឱ្យដើមចោទ។

២-ការទាមទារសំណងជម្ងឺចិត្តចំនួន ២០០០(ពីរពាន់)ដុល្លារអាមេរិក **ត្រូវច្រានចោល**។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩។ ករណីដែលបណ្ដឹងឧទ្ធរណ៍ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

| **ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខានិងត្រា: **សន លាង** | ហត្ថលេខា និងត្រា: **ឌៀន ស្រស់** |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បត្តិ៍ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ខេត្តព្រះវិហារ, ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩

| បានឃើញ | |
|---|---|
| **ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី** |
| ឌៀន ស្រស់ | សន លាង |

សម្គាល់៖ សាលក្រមនេះជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគំរូទេ